**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០១៩/១៩ ក.ប/ស.ជ.ណ.រ.ប.ប

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ និងសិស្ស-និស្សិតឱ្យចូលបម្រើការងារ ក្នុងក្របខ័ណ្ឌក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ឆ្នាំ២០១៩

**យោង៖** លិខិតលេខ ១០៩៧ មស.ក្រ.ខ ចុះថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់មន្ត្រីរាជការ សិស្ស-និស្សិត បុគ្គលិក ក្រុមហ៊ុន អង្គការ ឱ្យបានជ្រាបថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០១៩នេះ ត្រូវការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីចំនួន **១៤**កន្លែង ជាប្រភេទក្របខ័ណ្ឌ "ក" ដោយបែងចែកទៅតាមអង្គភាពដូចខាងក្រោម៖

| ល.រ | អង្គភាពជ្រើសរើស | ចំនួន | ជំនាញ |
|---|---|---|---|
| ១ | ទីស្តីការក្រសួង | ៧ | -ព័ត៌មានវិទ្យា - អក្សរសាស្ត្រអង់គ្លេស<br>-នីតិសាស្ត្រ -រដ្ឋបាលសាធារណៈ<br>-គ្រប់គ្រងទូទៅ -គណនេយ្យ<br>-ធនាគារ និងហិរញ្ញវត្ថុ -ទំនាក់ទំនងអន្តរជាតិ |
| ២ | មន្ទីរ ក.ប ខេត្តក្រចេះ | ១ | -ព័ត៌មានវិទ្យា - អក្សរសាស្ត្រអង់គ្លេស<br>-នីតិសាស្ត្រ -រដ្ឋបាលសាធារណៈ<br>-គ្រប់គ្រងទូទៅ -គណនេយ្យ |
| ៣ | មន្ទីរ ក.ប ខេត្តស្ទឹងត្រែង | ១ | |
| ៤ | មន្ទីរ ក.ប ខេត្តកោះកុង | ១ | |
| ៥ | មន្ទីរ ក.ប ខេត្តកំពង់ឆ្នាំង | ១ | |
| ៦ | មន្ទីរ ក.ប ខេត្តកែប | ១ | |
| ៧ | មន្ទីរ ក.ប ខេត្តឧត្តរមានជ័យ | ១ | |
| ៨ | មន្ទីរ ក.ប ខេត្តព្រះវិហារ | ១ | |
| **សរុប ១៤** (កន្លែង) | | | |

### ១-កម្រិតសញ្ញាបត្រ និងលក្ខខណ្ឌនៃការជ្រើសរើស

- បេក្ខជនត្រូវមានសញ្ជាតិខ្មែរ
- សញ្ញាបត្រយ៉ាងទាបបំផុតត្រឹមកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ



*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនជាមន្ត្រីរាជការ និងបេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីបណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនជាមន្ត្រីរាជការដែលបម្រើការងារនៅក្រសួង ស្ថាប័នផ្សេង ត្រូវមានលិខិតអនុញ្ញាតឱ្យប្រឡងពីក្រសួង ស្ថាប័ន និងត្រូវអនុញ្ញាតឱ្យផ្ទេរក្របខ័ណ្ឌនៅពេលប្រកាសលទ្ធផលប្រឡងជាប់ជាស្ថាពរ
- បេក្ខជនជាមន្ត្រីរាជការនឹងត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែតួនាទី ឬមុខតំណែងមិនត្រូវបានរក្សានោះទេ
- បេក្ខជនជាជនពិការដែលអាចបំពេញការងារបាន
- បេក្ខជនត្រូវមកដាក់ពាក្យសុំប្រឡងដោយផ្ទាល់ (មិនអនុញ្ញាតអោយមានអ្នកដាក់ជំនួស)
- ពេលមកដាក់ពាក្យសុំប្រឡង បេក្ខជនទាំងពីរភេទត្រូវនាំមកជាមួយនូវសញ្ញាបត្រច្បាប់ដើមដើម្បីបង្ហាញដល់មន្ត្រីទទួលពាក្យ
- ផ្តល់អាទិភាពដោយបន្ថែមពិន្ទុលើមធ្យមភាគចុងក្រោយនៃពិន្ទុសរុប ១០០% ចំពោះ៖

  ១/ បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឆ្នាំ២០១៩ បន្ថែម៥ពិន្ទុ

  ២/បេក្ខជនជាស្ត្រី.................................................................................................បន្ថែម២ពិន្ទុ

  ៣/បេក្ខជនជាជនពិការ...........................................................................................បន្ថែម៥ពិន្ទុ

ការបន្ថែមនេះ ផ្តល់ជូនបានតែមួយប្រភេទក្នុងករណីដែលបេក្ខជនមានលក្ខណៈសម្បត្តិលើសពី១ ដោយលក្ខខណ្ឌបន្ថែមពិន្ទុច្រើនជាងក្នុងចំណោមលក្ខខណ្ឌដែលបេក្ខជនមាន។

## ២-វិញ្ញាសា និងថេរវេលាប្រឡង

- ចំណេះដឹងទូទៅពាក់ព័ន្ធ រដ្ឋបាល និងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ................................................................................................................២ម៉ោង ០០នាទី មេគុណ៣
- ភាសាអង់គ្លេស (QCM).......................................................................................................................................................................................១ម៉ោង ៣០នាទី មេគុណ១។

## ៣-កាលបរិច្ឆេទលក់ពាក្យ-ទទួលពាក្យ និងឈប់ទទួលពាក្យ

- កាលបរិច្ឆេទលក់ពាក្យ និងទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះតទៅរៀងរាល់ម៉ោងធ្វើការ ពេលព្រឹកចាប់ពីម៉ោង ០៧:៣០-១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០-១៧:០០នាទី
- កាលបរិច្ឆេទឈប់ទទួលពាក្យ នៅថ្ងៃទី**៣០ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង១៧:០០នាទីល្ងាច**។

## ៤-កាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡង

- មណ្ឌលប្រឡងនឹងបិទផ្សាយនៅទីស្តីការក្រសួង**នាថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩**
- កាលបរិច្ឆេទប្រឡង**ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩**។

## ៥-សំណុំលិខិតចុះឈ្មោះប្រឡង

- ពាក្យសុំចុះឈ្មោះប្រឡង..................................................................................ចំនួន ០១ច្បាប់
- សេចក្តីចម្លងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងបរិញ្ញាបត្រ ឬអនុបណ្ឌិត ឬបណ្ឌិត ឬសញ្ញាបត្រដែលមានតម្លៃសមមូលដោយមានបញ្ជាក់ពីអាជ្ញាធរដែនដី..............................................ចំនួន ០១ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦..........................................................ចំនួន ០១ច្បាប់

- បង្កាន់ដៃបង់សិទ្ធិប្រឡង.......................................................................ចំនួន ០១ច្បាប់
- រូបថតថ្មី ៤x៦ ថតចំពីមុខគ្មានពាក់វ៉ែនតា ឬមួក............................................ចំនួន០២សន្លឹក
- លិខិតថ្កោលទោស(ក្រោយពេលប្រឡងជាប់ជាស្ថាពរ)...................................ចំនួន ០១ច្បាប់
- លិខិតពិនិត្យកាយសម្បទា(ក្រោយពេលប្រឡងជាប់ជាស្ថាពរ)...........................ចំនួន ០១ច្បាប់
- លិខិតអនុញ្ញាតឱ្យប្រឡងពីក្រសួង ស្ថាប័ន ឬអង្គភាពដែលកំពុងបម្រើការងារ ...............ចំនួន ០១ច្បាប់
- ប្រកាស/ស្ទើយប្រកាសស្តីពីការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាឆ្នាំ២០១៩ សម្រាប់បេក្ខជនជាមន្ត្រីជាប់កិច្ចសន្យា របស់ក្រសួង ឬអង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ..................ចំនួន០១ច្បាប់។

## ៦-កំណត់សំគាល់

- បេក្ខជនត្រូវសរសេរបំពេញពាក្យសុំប្រឡងដោយដៃ ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ និងមកដាក់ពាក្យដោយផ្ទាល់ ព្រមទាំងភ្ជាប់មកជាមួយនូវសញ្ញាបត្រច្បាប់ដើម និងឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងចំណុច "៥"។
- កន្លែងទំនាក់ទំនងផ្តល់ពាក្យ និងទទួលពាក្យប្រឡង៖

  ក/ សម្រាប់ទីស្តីការក្រសួង នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ***អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក (ទូរស័ព្ទ ០២៣ ៨៨៤ ៣៧៥) ជាន់ផ្ទាល់ដី*** ជាប់វិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

  ខ/ គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ដែលត្រូវជ្រើសរើស។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម មន្ត្រីរាជការ សិស្ស-និស្សិត បុគ្គលិកក្រុមហ៊ុន អង្គការ ដែលមានបំណងចង់ដាក់ពាក្យសុំប្រឡង មេត្តាជ្រាប និងអនុវត្តតាមការគួរ។

ថ្ងៃ [illegible] ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ក្រសួងព័ត៌មាន
- គ្រប់អង្គភាពចំណុះក្រសួង "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ